ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
នាយកដ្ឋានព័ត៌មាន

# សេចក្តីជូនព័ត៌មាន

## លទ្ធផលកិច្ចប្រជុំកំពូលយុទ្ធសាស្ត្រនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចអាយេយ៉ាវ៉ាឌី-ចៅប្រាយ៉ា-មេគង្គ លើកទី៨ និង កិច្ចប្រជុំកំពូលកម្ពុជា-ឡាវ-មីយ៉ាន់ម៉ា-វៀតណាម លើកទី៩ ថ្ងៃទី១៥-១៦ ខែមិថុនា ឆ្នាំ២០១៨ នៅទីក្រុងបាងកក ប្រទេសថៃ

--------

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានដឹកនាំគណៈប្រតិភូជាន់ខ្ពស់អញ្ជើញចូលរួមកិច្ចប្រជុំកំពូលយុទ្ធសាស្ត្រនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចអាយេយ៉ាវ៉ាឌី-ចៅប្រាយ៉ា-មេគង្គ (ACMECS) លើកទី៨ និងធ្វើជាប្រធានកិច្ចប្រជុំកំពូលកម្ពុជា-ឡាវ-មីយ៉ាន់ម៉ា-វៀតណាម (CLMV) លើកទី៩ ពីថ្ងៃទី ១៥ ដល់ថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ២០១៨ នៅទីក្រុងបាងកក ព្រះរាជាណាចក្រថៃ ។

១. កិច្ចប្រជុំកំពូល ACMECS លើកទី៨

ឯកឧត្តម ឧត្តមសេនីយ៍ ប្រាយុទ្ធ ច័ន្ទអូចា នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រថៃ បានធ្វើប្រធានកិច្ចប្រជុំកំពូល ACMECS លើកទី៨ ដែលបានប្រព្រឹត្តទៅពីថ្ងៃទី ១៥ ដល់ថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ២០១៨ ក្រោមមូលបទ "ឆ្ពោះទៅរកសហគមន៍មេគង្គ ដែលប្រកបដោយសមាហរណកម្ម និងតភ្ជាប់"។

នៅក្នុងកិច្ចប្រជុំកំពូល ថ្នាក់ដឹកនាំបានពិភាក្សា និងផ្លាស់ប្តូរទស្សនៈលើកិច្ចសហប្រតិបត្តិការក្នុងវិស័យអាទិភាពចំនួនប្រាំបី ដែលទទួលបានផ្លែផ្កាគួរឲ្យកត់សម្គាល់ រួមមានៈ ការតភ្ជាប់ការដឹកជញ្ជូន ការសំរួលពាណិជ្ជកម្មនិងវិនិយោគ ឧស្សាហកម្មនិងថាមពល កសិកម្ម ការអភិវឌ្ឍធនធានមនុស្ស ទេសចរណ៍ សុខាភិបាល និងបរិស្ថាន។

ថ្នាក់ដឹកនាំក៏បានគូសបញ្ជាក់ដោយការពេញចិត្តថា ACMECS នៅតែជាតំបន់ដែលមានសក្តានុពលធំធេង ហើយបំពេញតួនាទីជាកាតាលីករនៃតំបន់អាស៊ី ក្នុងការជម្រុញកំណើនសេដ្ឋកិច្ចតំបន់ និងពិភពលោក ដោយបានធ្វើឲ្យអនុតំបន់មានអាត្រាកំណើនប្រចាំឆ្នាំខ្ពស់ ជាមួយនឹងទីផ្សារធំធេង ធនធានមនុស្សប្រកបដោយជំនាញ ។ ថ្នាក់ដឹកនាំក៏បានទទួលស្គាល់ផងដែរថា អនុតំបន់នេះកំពុងជួបប្រទះនឹងបញ្ហាប្រឈមថ្មីៗ ដោយសារការរីកចំរើននៃសេដ្ឋកិច្ចសកលលោកមានសភាពយឺត

ជាងការរំពឹងទុក កំណើននិន្នាការគាំពារនិយមផ្នែកពាណិជ្ជកម្ម និងការប្រឆាំងសកលភាវូបនីយកម្ម។ ថ្នាក់ដឹកនាំក៏បានពិភាក្សាពីរបៀបដែលកិច្ចសហប្រតិបត្តិការ ACMECS និងការធ្វើសមាហរណកម្ម ជួយពន្លឿនការលូតលាស់សេដ្ឋកិច្ចនៅតាមព្រំដែន ក៏ដូចជារួមចំណែកក្នុងការពង្រឹងសន្តិភាព សន្តិសុខ ស្ថិរភាព និងវិបុលភាព នៅក្នុងតំបន់អាស៊ានទាំងមូល ។

កិច្ចប្រជុំកំពូល បានគូសបញ្ជាក់អំពីសារៈសំខាន់នៃកិច្ចសហប្រតិបត្តិការដែលអនុវត្តតាមរយៈ សសរស្តម្ភបីនៃផែនការមេរបស់ ACMECS រួមមាន៖

១) ACMECS ដែលមានភាពរលូនខាងការតភ្ជាប់៖ ជម្រុញការតភ្ជាប់ដោយរលូនតាមរយៈការ ដឹកជញ្ជូនពហុសណ្ឋាន (ការតភ្ជាប់ផ្លូវថ្នល់ ផ្លូវដែក ស្ពាន កំពង់ផែ ផ្លូវអាកាស ផ្លូវទឹក និងផ្លូវសមុទ្រ) រួមទាំងហេដ្ឋារចនាសម្ព័ន្ធដែលរៀបចំឡើងសម្រាប់ការតភ្ជាប់ឌីជីថលក្នុង អនុតំបន់ និងអន្តរតភ្ជាប់រចនាសម្ព័ន្ធថាមពល ។

២) ACMECS ដែលមានភាពស៊ីចង្វាក់៖ ជម្រុញការតភ្ជាប់ផ្នែកទន់ ដូចជា ១.កិច្ចសហប្រតិបត្តិការ ពាណិជ្ជកម្ម ឧស្សាហកម្ម និងវិនិយោគ ដែលសង្កត់ធ្ងន់ទៅលើកិច្ចសហប្រតិបត្តិការ គោលនយោបាយរបស់ ACMECS ក្នុងការធ្វើសុខដុមនីយកម្ម និងការរៀបចំវិធាន និង បទបញ្ញត្តិនានាឲ្យមានភាពងាយស្រួល ដើម្បីសម្រួលដល់ការបំលាស់ទីរបស់ប្រជាជន លំហូរទំនិញ សេវាកម្ម និងការវិនិយោគដោយសេរី និង ២.កិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុ រួមមានការបង្កើតមូលនិធិ ACMECS មូលនិធិហេដ្ឋារចនាសម្ព័ន្ធ និងបរធនបាលកិច្ច ACMECS ។

៣) ACMECS ដែលមានភាពឆ្លាតវៃ និងចីរភាព៖ លើកកម្ពស់ការអភិវឌ្ឍធនធានមនុស្សនៅ តាមវិស័យយុទ្ធសាស្ត្រនានា រួមមាន សហគ្រិនភាព កសិកម្ម ទេសចរណ៍ សេវាកម្ម វេជ្ជសាស្ត្រ និងអប់រំ និងជម្រុញកិច្ចសហប្រតិបត្តិការលើវិស័យបរិស្ថាន ថាមពល ឧស្សាហកម្ម ការប្រែប្រួលអាកាសធាតុ ការគ្រប់គ្រងហានិភ័យគ្រោះធម្មជាតិ ជាដើម ។

ក្នុងអំឡុងពេលកិច្ចប្រជុំកំពូល **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានធ្វើបទអន្តរាគមន៍ ដែលមាន ខ្លឹមសារសំខាន់ៗ ដូចខាងក្រោម៖

ទី១- កោតសរសើរចំពោះព្រះរាជាណាចក្រថៃ ដែលបានផ្តួចផ្តើមរៀបចំតាក់តែងផែនការមេ ACMECS ឆ្នាំ២០១៩-២០២៣ សំដៅកែលំអររចនាសម្ព័ន្ធប្រតិបត្តិការ ACMECS និងប្រើប្រាស់ សក្តានុពល ACMECS ឲ្យបានពេញលេញ ។ កម្ពុជាសូមឯកភាពជាគោលការណ៍លើគំនិតផ្តួចផ្តើម របស់ប្រទេសថៃ ក្នុងការបង្កើតមូលនិធិហេដ្ឋារចនាសម្ព័ន្ធ និងបរធនបាលកិច្ច ACMECS ។ ជាកិច្ចការ បន្ត ខ្ញុំសូមស្នើមន្ត្រីបច្ចេកទេសរបស់យើង ពិភាក្សា និងស្វែងយល់ឲ្យបានច្បាស់អំពីយន្តការ ទម្រង់ សមទ្ធិលទ្ធភាព និងលក្ខខណ្ឌយោងផ្នែកបច្ចេកទេសនៃមូលនិធិនេះ ដើម្បីអាចរៀបចំដាក់ឲ្យអនុវត្តបាន។

ទី២- វិស័យឯកជនមានតួនាទីសំខាន់ក្នុងការជម្រុញការអភិវឌ្ឍ ។ ដូចនេះ យើងត្រូវបន្តជម្រុញ ភាពជាដៃគូរវាងវិស័យសាធារណៈ និងវិស័យឯកជន ដែលជាកម្លាំងចលករនៃកំណើនសេដ្ឋកិច្ច និងត្រូវ បន្តផ្តល់អាទិភាពទៅលើការលំអរបរិស្ថានធុរកិច្ច ជាពិសេស តាមរយៈការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដឹក

ជញ្ជូន ការពង្រឹងប្រព័ន្ធឡូជីស្ទីក ការសម្រួលពាណិជ្ជកម្ម និងការជម្រុញកសាងតំបន់សេដ្ឋកិច្ចពិសេស។ បន្ថែមពីនេះ ចំពោះគម្រោងអាទិភាពដែលនៅសេសសល់ ពុំទាន់បានការគាំទ្រហិរញ្ញប្បទាន យើងគួរបន្តលើកទឹកចិត្ត និងជម្រុញបន្ថែមតាមរយៈការចូលរួមវិនិយោគពីវិស័យឯកជន ជាពិសេស ភាពជាដៃគូវិស័យឯកជន និងវិស័យសាធារណៈ ដើម្បីអាចសម្រេចបាននូវគម្រោងអាទិភាពទាំងនេះឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន ។ ខ្ញុំក៏សូមអបអរសាទរជោគជ័យនៃវេទិកានាយកប្រតិបត្តិ ACMECS ដែលត្រូវបានរៀបចំឡើងកាលពីម្សិលមិញ ក្រោមប្រធានបទ "ការតភ្ជាប់ទៅកាន់អនាគតរបស់យើងៈ បង្កើនកិច្ចសហប្រតិបត្តិការ និងសមាហរណកម្ម ACMECS" សំដៅលើកកម្ពស់ការតភ្ជាប់ បង្កើនពាណិជ្ជកម្ម និងការវិនិយោគ ព្រមទាំងលើកស្ទួយកិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុ ។

ទី៣- ការពង្រឹងកិច្ចសហប្រតិបត្តិការជិតស្និទ លើផ្នែកពាណិជ្ជកម្ម ការវិនិយោគ និងឧស្សាហកម្ម រវាងសមាជិកអនុតំបន់ ACMECS ក្នុងខ្សែច្រវាក់ផលិតកម្មតំបន់ និងសកលលោក គឺជាការងារដែលយើងត្រូវបន្តជម្រុញ ដើម្បីទទួលបានផលចំណេញពីការហៀរចេញនូវបច្ចេកវិទ្យា និងការផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ចរបស់ប្រទេសមួយចំនួននៅក្នុងតំបន់ ពីឧស្សាហកម្មពឹងផ្អែកលើពលកម្ម មកកាន់សេដ្ឋកិច្ចដែលពឹងផ្អែកលើមូលធន។ ទន្ទឹមនេះដែរ យើងត្រូវសម្របខ្លួនជាប្រចាំទៅនឹងលក្ខខណ្ឌថ្មី និងរក្សាបាននូវវិធានបទបើកចំហនិងទន់ភ្លន់ សម្រាប់ការផ្លាស់ប្តូរជាវិជ្ជមាន ជាពិសេស ការមកដល់នៃបដិវត្តន៍ឧស្សាហកម្មទី៤ និងការផ្លាស់ប្តូរក្នុងបច្ចេកវិទ្យាលើវិស័យសេវាកម្មហិរញ្ញវត្ថុ ដើម្បីធានាបានថាកម្លាំងផលិតកម្មរបស់យើងនៅតែធានាបាននូវភាពប្រកួតប្រជែង ។

ទី៤- ការថែរក្សាបាននូវសន្តិភាព សន្តិសុខ និងស្ថិរភាពក្នុងតំបន់និងអនុតំបន់ នៅតែជាការងារដ៏សំខាន់មួយសម្រាប់កិច្ចប្រឹងប្រែងអភិវឌ្ឍសង្គម-សេដ្ឋកិច្ចរបស់យើង ទាំងនៅក្នុងកម្រិតថ្នាក់ជាតិ និងអនុតំបន់ និងតំបន់ ។ ប្រការនេះ ទាមទារឲ្យយើងខិតខំថែមទៀត ក្នុងការពង្រឹងនូវទំនុកចិត្តទៅវិញទៅមក ដោយឈរលើអភិក្រមនៃការប្រើប្រាស់យន្តការដោះស្រាយវិវាទដោយសន្តិវិធី ការលើកកម្ពស់កិច្ចសន្ទនា និងការពិភាក្សារវាងគ្នានិងគ្នា ស្របតាមគោលការណ៍អន្តរជាតិ និងស្មារតីនៃកិច្ចសហការល្អ ។

ទី៥- ខ្ញុំសូមសម្តែងការគាំទ្រយ៉ាងពេញទំហឹង ចំពោះចក្ខុវិស័យរួមនៃការអភិវឌ្ឍនៅក្នុងបណ្តាប្រទេស ACMECS ជាពិសេស ខ្ញុំសូមគាំទ្រការអនុម័តសេចក្តីថ្លែងការណ៍ទីក្រុងបាងកក នៃកិច្ចប្រជុំកំពូល ACMECS លើកទី៨ និងផែនការមេ ACMECS ២០១៩-២០២៣ ។

នៅចុងបញ្ចប់នៃកិច្ចប្រជុំ ថ្នាក់ដឹកនាំក៏បានអនុម័តសេចក្តីថ្លែងការណ៍ទីក្រុងបាងកក និងផែនការមេ ACMECS ។

ក្នុងឋានៈជាប្រធានកិច្ចប្រជុំកំពូលប្តូរវេនរបស់ ACMECS នៅឆ្នាំ២០២០ នៅក្នុងសុន្ទរកថាទទួលតំណែងប្រធានកិច្ចប្រជុំ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានបញ្ជាក់សារជាថ្មីម្តងទៀត ពីការប្តេជ្ញាចិត្តរបស់កម្ពុជាក្នុងការពង្រឹងមិត្តភាពជាប្រពៃណី ភាពជាអ្នកជិតខាងល្អ និងការផ្តល់ផលប្រយោជន៍ទៅវិញទៅមក រវាងប្រទេស ACMECS ដើម្បីលើកកម្ពស់សន្តិភាព ស្ថិរភាព និងការអភិវឌ្ឍនៅក្នុងតំបន់។ កម្ពុជា នឹងត្រូវផ្តោតសំខាន់លើទិសដៅជាអាទិភាពរបស់ ACMECS ក្នុងការកាត់បន្ថយគម្លាតអភិវឌ្ឍន៍

និងលើកកម្ពស់វឌ្ឍនភាពសេដ្ឋកិច្ច-សង្គម រួមជាមួយការការពារ និងថែរក្សាបរិស្ថាន ដើម្បីពង្រឹងសុខមាលភាពប្រជាជន សម្រាប់ផលប្រយោជន៍រួមរបស់ ACMECS ។

កម្ពុជា នឹងជានាការអនុវត្តប្រកបដោយប្រសិទ្ធិភាពខ្ពស់ នូវសេចក្តីថ្លែងការណ៍ទីក្រុងបាងកក ផែនការមេ ACMECS ឆ្នាំ២០១៩-២០២៣ ដែលមានសសរស្តម្ភទាំងបី និងជម្រុញការបញ្ចប់ការអនុវត្តសេចក្តីថ្លែងការណ៍ទីក្រុងហាណូយ ក៏ដូចជាសេចក្តីថ្លែងការណ៍ផ្សេងទៀត រួមទាំងគម្រោង និងគំនិតផ្តួចផ្តើមទាំងឡាយ ដែលកំពុងត្រូវបានអនុវត្ត ទាំងកម្រិតទ្វេភាគី និងពហុភាគី ។

នៅក្នុងក្របខ័ណ្ឌកិច្ចប្រជុំកំពូល ACMECS លើកទី៨ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានថ្លែងសុទ្ធរកថាគន្លឹះនៅក្នុងវេទិកានាយកប្រតិបត្តិ ACMECS ដោយផ្តោតសំខាន់ទៅលើការជម្រុញកិច្ចសហប្រតិបត្តិការ និងសមាហរណកម្ម ACMECS ។ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់ពីកិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជា ដើម្បីជម្រុញ និងសម្រួលពាណិជ្ជកម្ម សម្រួលនីតិវិធីគយ លើកកម្ពស់ការតភ្ជាប់ស្ថាប័ន និងហេដ្ឋារចនាសម្ព័ន្ធរូបវន្តក្នុងវិស័យដឹកជញ្ជូនភ្ជាប់ជាមួយប្រទេសជិតខាង ដើម្បីសម្រេចឲ្យបាននូវចក្ខុវិស័យតភ្ជាប់ នៅក្រោមក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការ ACMECS និងអាស៊ានទាំងមូល ។

រាជរដ្ឋាភិបាលកម្ពុជា កំពុងពិនិត្យមើលសមទ្ធិលទ្ធភាព ក្នុងការកាត់បន្ថយអាត្រាពន្ធគយ ចាប់ពីឆ្នាំ២០១៩ តទៅ និងបង្កើនកិច្ចប្រឹងប្រែង ដើម្បីជម្រុញបន្ថែមទៀតនូវស្ថិរភាព និងគុណភាពការផ្គត់ផ្គង់អគ្គិសនី ក្នុងគោលបំណងទាក់ទាញការវិនិយោគក្នុងវិស័យឧស្សាហកម្ម ដែលមានតម្លៃបន្ថែមខ្ពស់ជាងមុន ព្រមទាំងការប្រើប្រាស់ម៉ាស៊ីននិងបច្ចេកវិទ្យាទំនើប ដែលជាផ្នែកមួយនៃខ្សែច្រវ៉ាក់តម្លៃតំបន់។

២. <u>កិច្ចប្រជុំកំពូល CLMV លើកទី៩</u>

នៅថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ២០១៨ **សម្តេចតេជោ ហ៊ុន សែន** បានធ្វើប្រធានកិច្ចប្រជុំកំពូល CLMV លើកទី៩ ក្រោមមូលបទ "**ដើម្បីសមាហរណកម្មសេដ្ឋកិច្ច និងការតភ្ជាប់កាន់តែខ្លាំងក្លា**" ។

ថ្លែងក្នុងពិធីបើកកិច្ចប្រជុំកំពូល **សម្តេចតេជោ** បានសម្តែងអំណរគុណចំពោះ **ឯកឧត្តម ឧត្តមសេនីយ៍ ប្រាយុទ្ធ ច័ន្ទអូចា** និងរាជរដ្ឋាភិបាលថៃ ដែលបានផ្តល់ទីកន្លែងសម្រាប់រៀបចំកិច្ចប្រជុំកំពូល CLMV លើកទី៩ នេះ ព្រមទាំងបដិសណ្ឋារកិច្ចយ៉ាងកក់ក្តៅដល់គណៈប្រតិភូទាំងអស់។

**សម្តេចតេជោ** បានសង្កត់ធ្ងន់អំពីសារៈសំខាន់នៃកិច្ចប្រជុំកំពូលក្នុងការស្វែងរកកាលានុវត្តភាពបន្ថែមទៀត ដើម្បីពង្រីកនិងពង្រឹងទំនាក់ទំនងពាណិជ្ជកម្ម ការវិនិយោគ ព្រមទាំងកិច្ចសហប្រតិបត្តិការស៊ីជម្រៅ តាមរយៈការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធ ទាំងផ្នែកទន់ និងរឹង ការអភិវឌ្ឍធនធានមនុស្ស ក្នុងបំណងលើកកម្ពស់សុខមាលភាព និងគុណភាពរស់នៅរបស់ប្រជាជននៃប្រទេស CLMV ឲ្យកាន់តែមានភាពល្អប្រសើរឡើង ។ គោលដៅនៃកិច្ចសហប្រតិបត្តិការ CLMV គឺផ្តោតអាទិភាពលើការពង្រឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងកំណែទម្រង់រចនាសម្ព័ន្ធស៊ីជម្រៅនៅក្នុងប្រទេសនីមួយៗ ក៏ដូចជាបន្តរឹតបន្តឹងកិច្ចសហប្រតិបត្តិការបន្ថែមទៀត ជាពិសេសកិច្ចសហប្រតិបត្តិការក្នុងវិស័យអាទិភាពទាំង៩ ដែលបានឯកភាពគ្នានាពេលកន្លងមក ។

កិច្ចប្រជុំកំពូលបានបង្ហាញឆន្ទៈ និងការប្តេជ្ញាចិត្ត ក្នុងការពង្រីកពាណិជ្ជកម្ម និងការវិនិយោគ កិច្ចសហប្រតិបត្តិការស៊ីជម្រៅក្នុងការតភ្ជាប់ទាំងផ្នែកទន់ និងរឹង លើកកម្ពស់ការអភិវឌ្ឍធនធានមនុស្ស លើកស្ទួយសុខុមាលភាព និងគុណភាពជីវិតរបស់ប្រជាជននៃប្រទេស CLMV ការអភិវឌ្ឍប្រកបដោយចីរភាព បរិយាប័ន្ន និងបញ្ជាក់អំពីការប្តេជ្ញាចិត្តក្នុងការសម្រេចឲ្យបានគោលដៅនៃកិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌ CLMV ។

ថ្នាក់ដឹកនាំបានកត់សម្គាល់ដោយការពេញចិត្តថា CLMV កំពុងស្ថិតលើមាគ៌ាដ៏ត្រឹមត្រូវនៃកំណើនសេដ្ឋកិច្ចរយៈពេលវែង ។ ជាចាំបាច់សម្រាប់ CLMV ក្នុងការបន្តជម្រុញកិច្ចសហប្រតិបត្តិការបន្ថែមទៀត ដើម្បីនាំយកមកនូវផ្លែផ្កាជាវិជ្ជមាននៃកាលានុវត្តភាពអភិវឌ្ឍន៍ និងសក្តានុពល និងមានជំនឿយ៉ាងមុតមាំថា CLMV នឹងជំនះការប្រឈមនានា តាមរយៈកិច្ចសហប្រតិបត្តិការកាន់តែជិតស្និទ និងការសម្របសម្រួលក្នុងចំណោមប្រទេស CLMV ។

កិច្ចប្រជុំកំពូលមានក្តីសោមនស្សរីករាយដោយបានកត់សម្គាល់ឃើញថា នាបណ្តាឆ្នាំកន្លងមកមិត្តភាព និងកិច្ចសហប្រតិបត្តិការក្នុងចំណោមប្រទេស CLMV មានការរីកចម្រើនយ៉ាងខ្លាំង។ ការកសាងសេដ្ឋកិច្ច ក៏ដូចជាហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ និងការតភ្ជាប់រវាងប្រជាជន និងប្រជាជន បានរួមវិភាគទានយ៉ាងធំធេងក្នុងការអភិវឌ្ឍសហគមន៍អាស៊ាន ការកាត់បន្ថយគម្លាតនៃការអភិវឌ្ឍ និងការលើកស្ទួយសុខមាលភាព និងជីវភាពរបស់ប្រជាជន ។

ថ្នាក់ដឹកនាំក៏បានពិភាក្សា និងផ្លាស់ប្តូរទស្សនៈ អំពីកិច្ចសហប្រតិបត្តិការលើវិស័យដឹកជញ្ជូន ពាណិជ្ជកម្ម និងការសម្រួលវិនិយោគ ឧស្សាហកម្ម ទេសចរណ៍ ធនធានមនុស្ស កសិកម្ម ថាមពល បច្ចេកវិទ្យាព័ត៌មានវិទ្យា ដែលជាកាតាលីករសម្រាប់ការអភិវឌ្ឍ CLMV និងបានដើរតួនាទីយ៉ាងសំខាន់ក្នុងការជម្រុញការលូតលាស់សេដ្ឋកិច្ច ក៏ដូចជានាំមកនូវភាពល្អប្រសើរសម្រាប់គុណភាពជីវិតរបស់ប្រជាជននៃប្រទេស CLMV ។

នៅចុងបញ្ចប់នៃកិច្ចប្រជុំ កិច្ចប្រជុំបានអនុម័តសេចក្តីថ្លែងការណ៍រួមកិច្ចប្រជុំកំពូល CLMV លើកទី៩ ។

នៅក្នុងសន្និសីទព័ត៌មានបន្ទាប់ពីកិច្ចប្រជុំកំពូលលើកទី៩ **សម្តេចតេជោ** បានគូសបញ្ជាក់ខ្លឹមសារសំខាន់ៗ ពីការប្តេជ្ញាចិត្តរបស់ CLMV នៅក្នុងការធ្វើកិច្ចសហប្រតិបត្តិការឲ្យកាន់តែស៊ីជម្រៅ ការសម្របសម្រួលយ៉ាងសកម្ម និងការលើកកម្ពស់ការតភ្ជាប់ CLMV យ៉ាងទូលំទូលាយ ក្នុងទិសដៅផ្សាភ្ជាប់សេដ្ឋកិច្ច និងប្រជាជនឲ្យកាន់តែជិតស្និទ តាមគោលដៅចម្បងៗ ដូចខាងក្រោម៖

១. ជម្រុញកិច្ចសហប្រតិបត្តិការវិស័យដឹកជញ្ជូន តាមរយៈការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធ និងជួយសម្រួលដល់ចរាចរណ៍ទំនិញឆ្លងកាត់ព្រំដែន និងការបម្លាស់ទីរបស់ប្រជាជននៃប្រទេស CLMV និងលើកកម្ពស់ពាណិជ្ជកម្មឆ្លងកាត់ព្រំដែន ។

២. អភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស ឬឧស្សាហកម្មពិសេស ជាយន្តការគាំទ្រសហគ្រាសធុនតូច និងមធ្យម លើកកម្ពស់ភាពជាសហគ្រិនវៃឆ្លាត ការកែលំអរផលិតភាព និងការធ្វើសុខដុមនីយកម្មក្នុងគោលដៅកាត់បន្ថយរបាំងបច្ចេកទេសសម្រាប់ពាណិជ្ជកម្ម ។

៣. កាត់បន្ថយឧបសគ្គដែលមិនចាំបាច់ លើកកម្ពស់ភាពជាដៃគូរវាងវិស័យសាធារណៈ និងឯកជន និងលើកកម្ពស់ការតភ្ជាប់ផ្លូវអាកាសក្នុងចំណោមប្រទេស CLMV ដើម្បីបង្កលក្ខណៈងាយស្រួលដល់ចរន្តនៃការធ្វើដំណើរនៅក្នុងតំបន់ CLMV និងដើម្បីទាក់ទាញភ្ញៀវទេសចរឲ្យចូលមកកាន់ប្រទេស CLMV កាន់តែច្រើន ។

៤. លើកកម្ពស់កិច្ចសហប្រតិបត្តិការលើការអភិវឌ្ឍធនធានមនុស្ស តាមរយៈការផ្លាស់ប្តូរបទពិសោធន៍ និងការអនុវត្តល្អ ជាពិសេស ការអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ លើកកម្ពស់កម្មវិធីរួមនៅតាមសាកលវិទ្យាល័យ CLMV និងនៅតាមវិទ្យាស្ថានបណ្តុះបណ្តាលភាសា រួមជាមួយកម្មវិធីផ្លាស់ប្តូរមន្ត្រីអប់រំ អ្នកជំនាញ គ្រូបង្រៀន អ្នកគ្រប់គ្រង និងនិស្សិត ព្រមទាំងការលើកកម្ពស់ការទទួលស្គាល់ទៅវិញទៅមកនូវគុណវឌ្ឍិគ្រូបង្រៀន និងអ្នកបណ្តុះបណ្តាលនៅក្នុងចំណោមប្រទេស CLMV ។

៥. លើកកម្ពស់ផលិតភាព និងពិពិធកម្ម លើកកម្ពស់ដំណាំកសិ-ឧស្សាហកម្មសម្រាប់ការនាំចេញ និងការកែច្នៃ ដោយពិចារណាទៅលើ "កិច្ចសន្យាកសិកម្ម" និងការជម្រុញកិច្ចសហប្រតិបត្តិការលើវិស័យជលផល និងរុក្ខាប្រម៉ាញ់ ជាពិសេសក្នុងផ្នែកស្រាវជ្រាវ និងអភិវឌ្ឍ។

៦. បង្កើនកិច្ចសហប្រតិបត្តិការវិស័យថាមពល ជាពិសេស តាមរយៈការតភ្ជាប់បណ្តាញអគ្គិសនី ការធ្វើពាណិជ្ជកម្ម និងការផ្លាស់ប្តូរថាមពល ព្រមទាំងការកសាងសមត្ថភាព និងជំនួយបច្ចេកទេស ដោយឈរលើគោលការណ៍ការអភិវឌ្ឍប្រកបដោយចីរភាព ការកាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមាន និងរៀបចំយុទ្ធសាស្រ្តអភិវឌ្ឍ ការចែកចាយថាមពលស្អាត ការកែលំអរប្រសិទ្ធិភាពថាមពល និងការអភិរក្ស ។

៧. បង្កើនការកសាងសមត្ថភាពជំនាញឌីជីថល ដើម្បីជម្រុញការរីកលូតលាស់នៃសេដ្ឋកិច្ចឌីជីថល លើកកម្ពស់ការតភ្ជាប់ និងសេវាកម្មបច្ចេកវិទ្យាព័ត៌មានវិទ្យាឆ្លងកាត់ព្រំដែន សំដៅលើកទឹកចិត្តសកម្មភាពសេដ្ឋកិច្ច និងពាណិជ្ជកម្មតាមប្រព័ន្ធអ៊ិនទើណែត ព្រមទាំងលើកទឹកចិត្តការផ្លាស់ប្តូរគ្នាទៅវិញទៅមកខាងផ្នែកសង្គម-វប្បធម៌ ជាមួយគ្នានេះ បន្តពង្រឹងថែមទៀតនូវកិច្ចសហប្រតិបត្តិការលើវិស័យសន្តិសុខតាមអ៊ិនទើណែត រួមបញ្ចូលទាំងលើកកម្ពស់កិច្ចសហការរវាងក្រុមឆ្លើយតបបញ្ហាបន្ទាន់នៃកុំព្យូទ័ររបស់ប្រទេស CLMV (CLMV CERTs) ផងដែរ ។

ក្រៅពីអញ្ជើញចូលរួមកិច្ចប្រជុំកំពូល CLMV លើកទី៩ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានអញ្ជើញចូលរួមពិសារអាហារពេលព្រឹកការងារជាមួយ **ឯកឧត្តម ថងលូន ស៊ីសូលីត** និង**ឯកឧត្តម ង្វៀន សួនហ៊្វុក** បានជួបពិភាក្សាទ្វេភាគីជាមួយ **ឯកឧត្តម ឧត្តមសេនីយ៍ ប្រាយុទ្ធ ច័ន្ទអូចា** ក្នុងគោលបំណងពង្រឹង និងធ្វើឲ្យកាន់តែស៊ីជម្រៅបន្ថែមទៀតនូវទំនាក់ទំនងទ្វេភាគីដ៏ល្អដែលមានស្រាប់រវាងប្រទេសទាំងពីរ និងបានអនុញ្ញាតឲ្យ **ឯកឧត្តម នាយឧត្តមសេនីយ៍ ឆាវ៉ាលីត យ៉ុងឆៃយុទ្ធ** អតីតនាយករដ្ឋមន្ត្រីថៃ ចូលជួបសម្តែងការគួរសម ផងដែរ ។

ថ្ងៃអង្គារ ៧កើត ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ២០១៨